**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.....................ន. គ. ស ......

# សេចក្ដីជូនដំណឹង
# ស្ដីពី
# ការទទួលយកមតិយោបល់ពីសាធារណជន
# ដើម្បីពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឱ្យបានជ្រាបថា÷ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើ “**ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា**” ដើម្បីពិនិត្យលទ្ធភាព និងភាពចាំបាច់ក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជានេះ។

ការផ្តល់មតិយោបល់របស់សាធារណជនទាំងអស់ ជាពិសេសម្ចាស់សហគ្រាស/ អាជីវកម្ម ផ្តល់មូលដ្ឋានយ៉ាងសំខាន់ដើម្បីអាចឱ្យ **ន.គ.ស** ពិនិត្យ និងសម្រេចលើការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា។ សូមសាធារណជនមេត្តាផ្តល់មតិយោបល់តាមរយៈការស្កេន QR Code ដែលបានភ្ជាប់មកជាមួយ។ ការផ្តល់មតិយោបល់នេះនឹងផុតកំណត់ត្រឹម**ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤**។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ : www.acar.gov.kh

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមផ្តល់មតិយោបល់ទៅលើស្តង់ដានេះឱ្យបានទាន់ពេលវេលាកំណត់។

ថ្ងៃ............ ខែ............ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ........ ឆ្នាំ ២០២៤

**និយ័តករគណនេយ្យនិងសវនកម្ម**

*សូមស្កេនQR Code ដើម្បីបញ្ចេញមតិយោបល់*

*សូមស្កេនQR Code ដើម្បីទាញយកឯកសារ*

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111